# ៣២ - រឿង ស្រីមាយាដកខ្វី



Tablets + o2 Go Flat
Exklusive Tablet-Angebote: Gerät + o2 Go Flat wählen & 240 € sparen.

មានបុរសម្នាក់ និងស្ត្រីម្នាក់ជាប្តីប្រពន្ធ នៅក្នុងស្រុកមួយ ប្តីជាមនុស្សចិត្តត្រង់ តែគ្មានប្រាជ្ញា ឯនាងប្រពន្ធនោះ ជាស្រីចិត្តមិនត្រង់នឹងប្តី តែងមានមាយាច្រើន ។ ថ្ងៃមួយនាងប្រពន្ធប្រាថ្នាចង់ជួបនឹងសាហាយណាស់ ដោយឃ្លាតគ្នាយូរហើយ តែមិនដឹងជាធ្វើដូចម្តេចនឹងទៅជួបបានដោយភូមិនោះឆ្ងាយពីគ្នា បើដើរទៅគេថាខ្មោចលង។ នាងប្រពន្ធក៏និយាយនឹងប្តីខ្លួនថា៖ «អ្នក! ល្ងាចនេះ យើងគិតទៅរកទិញមាន់មួយមកធ្វើស៊ី បានម្តង អ្នកចង់ស៊ីទេ?។ ប្តីតបវិញថា «ចង់ស៊ីដែរ» ប្រពន្ធថា «ខ្ញុំចង់ស៊ីខ្ទរខ្វី »។ ប្តីថា «អើ ! អញក៏ចង់ស៊ីខ្ទរខ្វីដែរ» ថាហើយក៏បបួលគ្នាចុះដើរទៅរកទិញមាន់អ្នកស្រុកនៅភូមិជិតផ្ទះសាហាយនោះ។
ប្តី និង ប្រពន្ធបបួលគ្នាសួររកទិញគ្រប់តែផ្ទះ។ នាងប្រពន្ធដើរបែកពីប្តីទៅជួប នឹងសាហាយវានិយាយកិច្ចកលផ្សេងៗរួចមកជួបនឹងប្តីវិញហើយប្រាប់ប្តីថា អ្នក!ផ្ទះឯណោះគេមានមាន់លក់គេប្រាប់ខ្ញុំម៉ិញ»។ ប្តីព្រមទៅតាមប្រពន្ធប្រាប់ក៏ទិញបានមេមាន់មួយយួរត្រលប់ទៅផ្ទះវិញ។ ពេលនោះជាពេលព្រលប់ ទៅដល់ពាក់កណ្តាលផ្លូវស្រាប់តែនាងប្រពន្ធធ្វើមាយាគត់ទ្រូងថា «ឱ! អ្នកអើយភ្លេចដូចគេលត់ទៅហើយ»។ ប្តីសួរថា «ភ្លេចអ្វី ?»។ ប្រពន្ធថា «ភ្លេចខ្វីទៅហើយអ្នក បើដូច្នោះអ្នកអែងនៅនេះសិនចុះ ខ្ញុំរត់ទៅវាឆាប់» ហើយនាងនោះរត់ទៅ ប្តីក៏ឈរចាំប្រពន្ធ។
ឯនាងប្រពន្ធកាលណាឃ្លាតពីប្តីហើយ ក៏គេចទៅជួបប្រុសសាហាយខ្លួន ហេតុតែរឭកសាហាយខ្លាំងណាស់ក៏ប្រះដេកទៅដីមិនរកផ្ទះសំបែងទេ ដោយប្រញាប់ទៅជួបប្តីវិញ។ ឯប្រុសសាហាយនោះក៏ទទួលភារៈនាងនោះទៅរួច នាងនោះយកខ្វីពីសាហាយហើយផ្តាំថា «ល្ងាចនេះអោយអ្នកឯងចាំមើល បើមានពេលស្រួលចូលទៅដេកម្តងទៀតចុះ» និយាយកិច្ចការសព្វគ្រប់ ហើយនាងនោះក៏ត្រលប់មកឯប្តីដើម។
កាលដែលនាងប្រះដេកនោះ ដីក៏នៅប្រលាក់ជាប់ នឹងខ្នងមិនទាន់បោសនៅឡើយ ព្រោះដើរមកដោយប្រញាប់ លុះដើរមកដល់ប្តីខ្លួនហើយក៏សើចក្អាកក្អាយ និយាយទៅកាន់ប្តីខ្លួនថា «អ្នកឃើញម៉ិញប្រហែលជាសើចដាច់ខ្យល់ហើយ»។ ប្តីសួរថា «សើចអី ?»។ ប្រពន្ធតបថា «ឯអ្នកមើលខ្នងខ្ញុំ បោសអោយបន្តិចណា! ហ្នឹងហើយខ្ញុំដកខ្វីទៅ វារបូតដៃទាំងអស់មក ខ្ញុំដួលផ្ងារទៅក្រោយបះជើងប្រេាង បានជាប្រលាក់ខ្នងខ្ញុំអស់»។
ប្តីមិនដឹងក៏បោសខ្នងអោយប្រពន្ធទៅរួចហើយនាំគ្នាដើរទៅផ្ទះ ធ្វើបាយ និងធ្វើមាន់ស៊ី ធ្វើរួចហើយពេលងងឹតស៊ីបាយរួចប្រពន្ធនិយាយនឹងប្តីថា «អ្នកផ្លុំប៉ិទៅខ្ញុំនឹងស្តាប់» ប្តីក៏យកប៉ិមកផ្លុំ។ ប្រពន្ធដេកស្តាប់ៗ បន្តិចទៅក៏កិលមកដេកលើភ្លៅប្តីហើយថា «ពិរោះណាស់អ្នក ! អ្នកផ្លុំប៉ិមើលរន្ធដែររឺទេ ? បើអ្នកមិនមើលរន្ធ ធ្វើម្តេចនឹងចាប់បើកបិទត្រូវទំនុក ?»។ ប្តីតបថា «ទេមិនបាច់មើលរន្ធទេ ព្រោះដៃចាំស្ទាត់ហើយ ចំនាំរន្ធផង»។ ប្រពន្ធថា «បើដូច្នេះខ្ញុំបិទភ្នែកអ្នកទាំងពីរមើលអ្នកនៅតែផ្លុំពិរោះដដែលរឺទេ?។ ប្តីតបថា «បិទចុះ ផ្លុំក៏នៅពិរោះដូចមុនដែរ»។
ប្រពន្ធយកដៃបិទភ្នែកប្តីខ្លួនទាំងពីរ រួចហើយក៏កន្ទែកជើងអោយសាហាយនោះឃើញ។ ប្រុសសាហាយឃើញ សាហាយខ្លួនបិទភ្នែកប្តីបានហើយ កន្ទែកជើងអោយសញ្ញាដូច្នោះ ក៏ចូលទៅរួមសង្វាសនឹងនាងនោះទៀត ។ លុះសាហាយនោះថយចេញ ទើបប្រពន្ធលែងបិទភ្នែកប្តី។ ប្តីនោះក៏មិនដឹងដល់ កិច្ចកលនោះឡើយ ។ ព្រោះហេតុនេះ បានជាមានពាក្យបុរាណថា មាយាដកខ្វីមាន

ទាំងទំនុកច្រើនផងថា ៖

> *«ស្រីអើយនាងស្រី ស្រស់ទៅដកខ្ញី ដកដួលទាំងខ្លួន កាលដកលើកមុន តូចតន់លាក់ខ្លួន ដកក្រោយសំនួន ផ្ជូនឲ្យប្តីស្លាប់។ ប្តីនាងអ្នកផ្តុំ នាងសុំធ្វើគ្រាប់ បន្ទរអឺងអាប់ ចប់បទអុំទូក»។*

**កុំពត់ស្រលៅ កុំប្រដៅស្រីខូច**

g+1 +2 Recommend this on Google

# Neue Domains bei STRATO

DE-Domain bis 02.08. nur 0,25€ mtl. Das Internet weiß, was du brauchst.

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address...

ចង់បាន

នាំមកជូនលោកអ្នកដោយ

